# ការផ្តល់សេវាទឹកស្អាតដោយរដ្ឋបាលថ្នាក់ក្រោមជាតិ៖

## “កិច្ចសហការរវាងរដ្ឋបាលស្រុក និងអាជីវករក្នុងមូលដ្ឋាន”

**ស្ថានីយបានស័ក្តិ** គឺជាឈ្មោះស្ថានីយផលិតទឹកស្អាតមួយកន្លែង ដែលជាទីសាកល្បងលើកដំបូងនូវការផ្តល់សេវាទឹកស្អាតដោយរដ្ឋបាលស្រុក ក្រោមកិច្ចសហការភាពជាដៃគូជាមួយនឹងអាជីវករផលិតទឹកស្អាតនៅក្នុងមូលដ្ឋាន។ ស្ថានីយនេះបានសម្ភោធដាក់ឱ្យដំណើរការជាផ្លូវការ និងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងវិនិយោគរួមរវាងរដ្ឋបាលស្រុករុក្ខគិរី ខេត្តបាត់ដំបង និងអាជីវករដែលបានទទួលអាជ្ញាបណ្ណពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣។ បន្ទាប់ពីទទួលបាននូវការផ្ទេរមុខងារ ធនធាន សិទ្ធិអំណាច និងស្វ័យភាពដល់រដ្ឋបាលស្រុកក្រោមកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រដ្ឋបាលស្រុករុក្ខគិរីបានចាប់ដៃសហការវិនិយោគរួមជាមួយវិស័យឯកជនក្នុងមូលដ្ឋាន ដើម្បីជំរុញការផ្តល់សេវាទឹកស្អាតដែលជាតម្រូវការចាំបាច់បំផុតក្នុងមូលដ្ឋានរបស់ខ្លួនជូនដល់ប្រជាពលរដ្ឋ។



**វិបត្តិទឹកស្អាត** ដែលពុំមានសុវត្ថិភាពសម្រាប់ការប្រើប្រាស់ គឺជាបញ្ហាប្រឈមចម្បង និងមិនត្រូវបានដោះស្រាយជាយូរណាស់មកហើយ ហើយក៏បានបង្កជាផលវិបាកជាច្រើនដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋានស្រុករុក្ខគិរីដែលទើបកកើតថ្មី និងហ៊ុមព័ទ្ធទៅដោយភ្នំ។ តម្លៃវិនិយោគខ្ពស់លើការសាងសង់ស្ថានីយផលិតទឹកស្អាត



និងការតភ្ជាប់បណ្តាញទឹកនៅក្នុងតំបន់ដាច់ស្រយាលដែលមានប្រជាជនរស់នៅរាយប៉ាយ សណ្ឋានដីខ្ពស់ដែលត្រូវការកម្លាំងសម្ពាធខ្ពស់ដើម្បីរុញទឹក មិនមានប្រភពទឹកលើដីគ្រប់គ្រាន់ ប្រភពទឹកក្រោមដីមិនមានសុវត្ថិភាពសម្រាប់ប្រើប្រាស់ ជាពិសេសការប្រឈមនឹងការប្រែប្រួលអាកាសធាតុកាន់តែធ្ងន់ធ្ងរ បានជំរុញឱ្យមានការចំណាយលើថ្លៃទឹកកាន់តែច្រើនឡើង និងការប្រមូលចំណូលពីការវិនិយោគមានរយៈពេលវែង គឺជាមូលហេតុដែលអាជីករផលិតទឹកស្អាតមិនមានលទ្ធភាពក្នុងការវិនិយោគបើទោះជាពួកគាត់ទទួលបានអាជ្ញាបណ្ណវិនិយោគក៏ដោយ។

ដើម្បីលើកកម្ពស់សេដ្ឋកិច្ចមូលដ្ឋាន ពង្រឹងសមត្ថភាពបន្សាំរបស់ប្រជាពលរដ្ឋ និងសុខុមាលភាពប្រជាពលរដ្ឋ លេខាធិការដ្ឋាន គ.ជ.អ.ប. សហការជាមួយអង្គការ UNCDF បានកៀរគរការគាំទ្រថវិកាពីក្រសួងបរិស្ថាននៃសាធារណៈរដ្ឋកូរ៉េ ផ្តល់នូវការវិនិយោគលើការសាងសង់ស្ថានីយផលិតទឹកស្អាត និងបណ្តាញមួយចំនួនដល់រដ្ឋបាលស្រុករុក្ខគិរី ព្រមទាំងបានកៀរគរការចូលរួមពីវិស័យឯកជនក្នុងការប្រតិបត្តិការលើការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋក្នុងភូមិគោលដៅក្នុងឃុំបាសាក់ ស្រុករុក្ខគិរី ខេត្តបាត់ដំបង។

**ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន** បានរៀបចំឡើងក្រោមកិច្ចព្រមព្រៀងវិនិយោគរួមរវាងរដ្ឋបាលស្រុករុក្ខគិរី ដោយលោកស្រី ប៊ិន បូឡែន និងអាជីវករ ដោយលោកស្រី ឆាង សោភា គឺជាការសាកល្បងជាលើកដំបូងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន។ គំរូនៃកិច្ចសហការវិនិយោគនេះ បានជំរុញឱ្យមានភាពជាម្ចាស់ក្នុងការផ្តល់

សេវាសាធារណៈរបស់រដ្ឋបាលមូលដ្ឋាន ដោយកៀរគរការចូលរួមវិនិយោគជាមួយវិស័យឯកជនក្នុងមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងចូលរួមចំណែកក្នុងការសម្រេចបាននូវគោលដៅផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យជនបទរបស់រាជរដ្ឋាភិបាលកម្ពុជា។



ការគ្រប់គ្រងកិច្ចប្រតិបត្តិការនៃការវិនិយោគស្ថិតក្រោមការដឹកនាំផ្ទាល់ដោយគណៈកម្មការវិនិយោគរួម ដែលមានសមាសភាពពីរដ្ឋបាលស្រុករុក្ខគិរី រដ្ឋបាលឃុំបាសាក់ និងអាជីវករ។ គណៈកម្មការបានជ្រើសរើសអ្នកគ្រប់គ្រងស្ថានីយមួយរូបជាសេនាធិការលើការប្រតិបត្តិការប្រចាំថ្ងៃលើការផលិត ការចែកចាយ ត្រួតពិនិត្យតាមដានគុណភាពទឹក និងគ្រប់គ្រងចំណូលចំណាយនៅក្នុងស្ថានីយ។

ក្រោមកិច្ចសហការវិនិយោគ គណៈកម្មការវិនិយោគរួម ធ្វើការពិនិត្យអនុម័តលើផែនការវិនិយោគ និងរបាយការណ៍ចំណូលចំណាយ ព្រមទាំងផ្តល់ការលើកទឹកចិត្តលើការអនុគ្រោះដល់ប្រជាពលរដ្ឋក្រីក្រលើតម្លៃតភ្ជាប់បណ្តាញ និងការផ្តល់សេវាទឹកស្អាតដល់ស្ថាប័នសាធារណៈនានាក្នុងមូលដ្ឋាន។



**លោកស្រី ប៊ិន ប៊ូឡែន**

**អភិបាលនៃគណៈអភិបាលស្រុកស្រុករុក្ខគិរី**



**លោកស្រី ឆាង សោភា**

**អាជីវករទឹកស្អាត**

**ការពង្រឹងសមត្ថភាពស្ថាប័ន** ដែលអ្នកបច្ចេកទេសនៃរដ្ឋបាលស្រុក រដ្ឋបាលឃុំ និងអាជីវករបានទទួលការបណ្តុះបណ្តាលពីក្រុមហ៊ុន K-Water ទាំងនៅក្នុងប្រទេស និងនៅសាធារណរដ្ឋកូរ៉េ លើការគ្រប់គ្រង ប្រតិបត្តិការ ការថែទាំ ការផលិត និងការត្រួតពិនិត្យលើការផលិតទឹកស្អាត និងមានសុវត្ថិភាពសម្រាប់ការប្រើប្រាស់បានចូលរួមចំណែកក្នុងការពង្រឹងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការវិនិយោគលើវិស័យទឹកស្អាត។

ទន្ទឹមនេះ គំរូវិនិយោគរួមនៅរដ្ឋបាលថ្នាក់ក្រោមជាតិនឹងក្លាយជាជម្រើសដំណោះស្រាយមួយថ្មីបន្ថែមទៀតសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងប្រទេសកម្ពុជាដែលកំពុងប្រឈមនឹងកង្វះការផ្គត់ផ្គង់ទឹកស្អាតក្នុងមូលដ្ឋាន ព្រមទាំងជាករណីសិក្សាបន្ថែមទៀតដែលអាចជាជំនួយដល់ការងារកំណែទម្រង់អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិក្នុងប្រទេសកម្ពុជាផងដែរ៕

**គាំទ្រ សម្របសម្រួល និងអនុវត្តដោយ៖**

គជអប NCDD · UN CDF · 환경부 Ministry of Environment · K water